Declassified to Public
12 June 2020

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 19 / 08 / 2016
ម៉ោង (Time/Heure) : 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លេខ៖ D296/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

## ដីកាសម្រេចលើសំណើរបស់ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាព កំណត់ហេតុនៃការស្តាប់ចម្លើយដែលមិនបានថតសំឡេង

---

**<u>ផ្ញើជូន៖</u>**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេទ្នី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រ៊ីនណា
វ៉េន ពៅ

Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ស.ច.ស Mark Harmon និង យូ ប៊ុនឡេង បានចេញសេចក្តីណែនាំទៅអ្នកស៊ើបអង្កេតទាំងអស់នៅការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស" ) ដោយបញ្ជាក់ថា លែងតម្រូវឱ្យថតយកសំឡេង ឬរូបភាពនៃការស្តាប់ចម្លើយសាក្សីទៀតហើយ ដោយពិនិត្យឃើញថា នេះមិនមែនជាការអនុវត្តដែលតម្រូវឱ្យមានដាច់ខាតតាមវិធានផ្ទៃក្នុងឡើយ("សេចក្តីណែនាំថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២")[1]។

៣. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥ ដោយបានពិភាក្សាបញ្ហានេះជាមួយនឹងចៅក្រម យូ ប៊ុនឡេង ខ្ញុំបានចេញសេចក្តីណែនាំទៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដោយចាប់ផ្តើមឡើងវិញនូវការអនុវត្តថតយកសំឡេងនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់("សេចក្តីណែនាំថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥")[2]។

៤. នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ខ្ញុំបានចេញសេចក្តីណែនាំបន្ថែមទៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ស្តីពីការសម្រិតសម្រាំងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងស្តីពីទម្រង់នៃកំណត់ហេតុស្តាប់ចម្លើយ("សេចក្តីណែនាំថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥")[3]។

៥. នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៥ មេធាវីការពារក្តី អោ អាន ("មេធាវីការពារក្តី") បានដាក់សំណើសុំបកប្រែ និងធ្វើប្រតិចារឹកខ្សែអាត់សំឡេង និងសុំដាក់ឯកសារមួយចំនួនចូលក្នុងសំណុំរឿង ("សំណើសុំធ្វើប្រតិចារឹក")[4]។

---

[1] សំណុំរឿង ០០៤ ឯកសារ D116 *សេចក្តីណែនាំស្តីពីការស្តាប់ចម្លើយសាក្សី* ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ១។

[2] សំណុំរឿង០០៤ ឯកសារD266 *អនុស្សរណៈពី ស.ច.ស.អ ផ្ញើជូន អ្នកស៊ើបអង្កេតទាំងអស់របស់ ក.ស.ច.ស ទាក់ទងនឹង"សេចក្តីណែនាំស្តីពីការថតការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី"* ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ទំព័រ ១។

[3] សំណុំរឿង ០០៤ ឯកសារ D269 *អនុស្សរណៈពី ស.ច.ស.អ ផ្ញើជូន អ្នកស៊ើបអង្កេតទាំងអស់របស់ ក.ស.ច.ស ទាក់ទងនឹងសេចក្តីណែនាំស្តីពីការសម្រិតសម្រាំងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផ្សេងទៀត និងស្តីពីទម្រង់នៃកំណត់ហេតុស្តាប់ចម្លើយ* ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥។

៦. នៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ មេធាវីការពារក្ដី បានដាក់សំណើសុំឱ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ធ្វើមោឃភាពកំណត់ហេតុនៃការស្ដាប់ចម្លើយដែលមិនបានថតសំឡេង("សំណើសុំមោឃភាព")[5]។

៧. នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦ ខ្ញុំបានចេញដីកាសម្រេចបដិសេធសំណើសុំធ្វើប្រតិចារឹក ("ដីកាសម្រេចលើសំណើសុំធ្វើប្រតិចារឹក")[6]។

## II. **សារណា**

៨. នៅក្នុងសំណើសុំមោឃភាព មេធាវីការពារក្ដី អះអាងថា ការអនុវត្តរបស់ ក.ស.ច.ស ដែលមិនថតសំឡេងការស្ដាប់ចម្លើយសាក្សី គឺជាកំហុសនីតិវិធី ដោយសារថា ការមិនបានថតសំឡេងការស្ដាប់ចម្លើយ ធ្វើឱ្យ ស.ច.ស *"មិនអាច"*បញ្ជាក់ថាតើកំណត់ហេតុស្ដាប់ចម្លើយពិតជាឆ្លុះបញ្ចាំងពីអ្វីដែលបានបញ្ជាក់នៅក្នុងការស្ដាប់ចម្លើយសាក្សីដែរឬអត់[7]។

៩. មេធាវីការពារក្ដី អះអាងថា ការថតសំឡេងការស្ដាប់ចម្លើយគឺជាឆន្ទានុសិទ្ធិតាមវិធានផ្ទៃក្នុង ២៥(៤) ប៉ុន្តែ *"កាលៈទេសៈពិសេស"*នៃសំណុំរឿង ០០៤ តម្រូវថា ឆន្ទានុសិទ្ធិរបស់ ស.ច.ស ដែលមិនឱ្យថតសំឡេងការស្ដាប់ចម្លើយ ត្រូវបានកម្រិតតាមលក្ខខណ្ឌតម្រូវសម្រាប់កិច្ចស៊ើបសួរស្វែងរកការពិត និងដោយមិនលម្អៀង និងលក្ខខណ្ឌតម្រូវសម្រាប់កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព[8]។ កាលៈទេសៈពិសេសដែលមេធាវីការពារក្ដី បានលើកឡើង គឺ៖ (i) ការបង្ហាញរបស់មេធាវីការពារក្ដីនៅក្នុងសំណើសុំធ្វើប្រតិចារឹក អំពីភាពមិនត្រឹមត្រូវមួយចំនួននៅក្នុងការស្ដាប់ចម្លើយដែលបានថតសំឡេង ហើយភាពមិនត្រឹមត្រូវនេះគឺជាករណីដែលកិច្ចស៊ើបសួរបានធ្វើឡើងនៅក្រៅក្របខណ្ឌច្បាប់ជាធរមាន និងធ្វើឱ្យមានបញ្ហាចោទសួរអំពី

---

[4]សំណុំរឿង ០០៤ ឯកសារ D274 *សំណើសុំការបកប្រែ និងការធ្វើប្រតិចារឹកនៃខ្សែអាត់ថតសំឡេង និងសំណើសុំដាក់ឯកសារមួយចំនួនក្នុងសំណុំរឿង* ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០១៥។

[5] សំណុំរឿង ០០៤ ឯកសារ D296 *សំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកំណត់ហេតុនៃការស្ដាប់ចម្លើយដែលមិនមានខ្សែអាត់សំឡេង* ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៦។

[6] សំណុំរឿង ០០៤ ឯកសារ D274/1 *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបកប្រែ និងធ្វើប្រតិចារឹកខ្សែអាត់ថតសំឡេង និងដាក់ឯកសារមួយចំនួនក្នុងសំណុំរឿង* ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦។

[7] សំណើសុំមោឃភាព កថាខណ្ឌ ២, ២០ និង ២៧។

[8] សំណើសុំមោឃភាព កថាខណ្ឌ ២១, ២៤ និង ២៦។

ភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ និងភាពអាចទុកចិត្តបានទៅលើខ្លឹមសារភស្តុតាងរបស់សាក្សី[9] (ii)ការចេញសេចក្តីណែនាំថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១២ ដែលមិនបានធ្វើឱ្យមានតុល្យភាពត្រឹមត្រូវរវាងសិទ្ធិរបស់ អោ អាន យោងតាមវិធានផ្ទៃក្នុង ២១ ជាមួយនឹងតម្រូវការត្រូវមានកិច្ចដំណើរការនីតិវិធីយ៉ាងឆាប់រហ័ស[10] និង (iii) ការចេញសេចក្តីណែនាំថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៥ ដែលបានបង្កើតឱ្យមានស្ថានភាពការងារមិនត្រឹមត្រូវ និងបែកខ្ញែកគ្នាសម្រាប់លទ្ធភាពរបស់ ស.ច.ស ក្នុងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយទាក់ទងនឹងការស្តាប់ចម្លើយសាក្សីពាក់ព័ន្ធនឹងការចោទប្រកាន់មកលើ អោ អាន[11]។

១០. មេធាវីការពារក្តី បញ្ជាក់ថា វិការៈដែលខ្លួនបានបង្ហាញនៅក្នុងសំណើសុំធ្វើប្រតិចារឹក បង្ហាញពី"*បញ្ហាជាប្រព័ន្ធ និងទូលំទូលាយ*"នៅក្នុងនីតិវិធី និងបច្ចេកទេសស្តាប់ចម្លើយរបស់ ក.ស.ច.ស ដែលមិនឱ្យសន្និដ្ឋានបានថាមានភាពប្រក្រតីនៅក្នុងកិច្ចស៊ើបសួររបស់ ក.ស.ច.ស ឡើយ[12]។ ដោយពិនិត្យមើលកាលៈទេសៈដែលបានចោទប្រកាន់បែបនេះ ទើបការស្តាប់ចម្លើយណាដែលមិនបានថតសំឡេង ត្រូវតែចាត់ទុកថាមានកំហុសនីតិវិធី[13]។

១១. មេធាវីការពារក្តី អះអាងថា កំហុសនីតិវិធីដែលបានចោទនេះ រំលោភសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងតម្លាភាព សិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងសិទ្ធិសួរដេញដោលសាក្សីដាក់បន្ទុកលើរូបគាត់ យោងតាមមាត្រា ១៤(៣)នៃ *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ("ICCPR")[14]។ ការអះអាងនេះគឺផ្អែកលើមូលដ្ឋានដែលថា ការមិនបានថតសំឡេងបានរារាំង អោ អាន មិនឱ្យពិនិត្យមើលការអនុវត្តការងាររបស់ ក.ស.ច.ស មិនឱ្យទទួលបានភស្តុតាងដោះបន្ទុកសក្តានុពល ឬឯកសារផ្សេងទៀតដែលចាំបាច់សម្រាប់រៀបចំការពារក្តី អោ អាន និងមិនឱ្យរៀបចំការពារក្តីគាត់ ឱ្យបានត្រឹមត្រូវដោយគ្មានការដាក់

---

[9] សំណើសុំមោឃភាព កថាខណ្ឌ ២១, ២២ និង ៣១។

[10] សំណើសុំមោឃភាព កថាខណ្ឌ ២១, ២៥ និង ៣៧។

[11] សំណើសុំមោឃភាព កថាខណ្ឌ ២១ និង ២៣។

[12] សំណើសុំមោឃភាព កថាខណ្ឌ ២២។

[13] សំណើសុំមោឃភាព កថាខណ្ឌ ២៦។

[14] សំណើសុំមោឃភាព កថាខណ្ឌ ៣, ១៤ និង ២៩។

កម្រិតចំពោះលទ្ធភាពអាចដាក់ទឡ្ហីករណ៍ការពារក្តីទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[15]។

១២. មេធាវីការពារក្តី បញ្ជាក់ថា យោងតាមវិធានផ្ទៃក្នុង ៧៦(២) ការធ្វើមោឃភាពការស្តាប់ចម្លើយសាក្សីដែលមិនបានថតសំឡេងពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង អោ អាន គឺជាដំណោះស្រាយសមស្របតែមួយគត់នៅក្នុងកាលៈទេសៈនេះ[16]។ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយចំនួន ៣៥៤ ដែលមេធាវីការពារក្តី ចាត់ទុកថាពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង អោ អាន មេធាវីការពារក្តី អះអាងថា យ៉ាងហោចណាស់ មានកំណត់ហេតុស្តាប់ចម្លើយចំនួន ១៩៥ (គឺ ៥៥%) ដែលមិនមានខ្សែអាត់សំឡេង[17]។

## III. ពិភាក្សា

១៣. នៅពេលដែលទទួលពិនិត្យពាក្យសុំដែលបានដាក់តាមវិធានផ្ទៃក្នុង ៧៦(២) ស.ច.ស ចាំបាច់ត្រូវជឿជាក់ថា ពាក្យសុំនោះមានសំអាងហេតុដែលបញ្ជាក់ថា (i) មានករណីកំហុសនីតិវិធី និង (ii) កំហុសបែបនោះរំលោភសិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំ[18]។ លក្ខខណ្ឌនេះពាក់ព័ន្ធនឹងការសេចក្តីសម្រេចថាតើ អ្នកដាក់ពាក្យសុំ មាន"ករណីដែលអាចជំទាស់តវ៉ាបាន"ដែរឬអត់ ប៉ុន្តែ មិនអនុញ្ញាតឱ្យត្រួតពិនិត្យមើលអង្គសេចក្តីនៃពាក្យសុំឡើយ[19]។ នៅក្នុងការវាយតម្លៃថាតើមានករណីដែលអាចជំទាស់តវ៉ាបានដែរឬអត់នោះ ជាការសមស្របដែល ស.ច.ស ត្រូវជឿជាក់ថា "*ពាក្យសុំមានហេតុផលគ្រប់គ្រាន់នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយត្រូវ*

---

[15] សំណើសុំមោឃភាព កថាខណ្ឌ ៣0 និង ៣២។

[16] សំណើសុំមោឃភាព កថាខណ្ឌ ៣ និង ៤0។

[17] សំណើសុំមោឃភាព កថាខណ្ឌ ២៣។

[18] សំណុំរឿង00២ ឯកសារ D263/2/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1)* ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២0១0 កថាខណ្ឌ ១៨។ សំណុំរឿង00៣ ឯកសារ D134/1/10 *សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [កោសលុប] ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ [កោសលុប]ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ* ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២0១៥ កថាខណ្ឌ ១៩។

[19] ដូចជើងទំព័រខាងលើ។

*បង្ហាញអំពីកំហុសនីតិវិធីដែលចោទប្រកាន់ និងការខូចខាត ប្រសិនបើមាន ដែលជនត្រូវចោទបានទទួលរងដោយសារតែកំហុសនីតិវិធីនោះ*"[20]។

១៤. នៅក្នុងសំណើសុំមោឃភាព មេធាវីការពារក្តី បង្ហាញថាជាកំហុសនីតិវិធីទូទៅចំពោះអង្គហេតុដែលថា មេធាវីការពារក្តី មិនអាចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃកំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៤ ពាក់ព័ន្ធនឹងការចោទប្រកាន់មកលើ អោ អាន ក្នុងករណីដែលមិនមានខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ។

១៥. ជាដំបូង ខ្ញុំកត់សម្គាល់ថា តាមវិធានផ្ទៃក្នុង មិនមានលក្ខខណ្ឌតម្រូវត្រូវថតសំឡេងការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ឡើយ។ សេចក្តីសម្រេចមិនថតសំឡេងការស្តាប់ចម្លើយបែបនេះ នឹងមិនមែនជាកំហុសនីតិវិធីឡើយ។ ប៉ុន្តែ អ.ប.ជ បានបញ្ជាក់ថា *"ការបង្ហាញអំពីការរំលោភសិទ្ធិរបស់ជនត្រូវចោទ ដែលត្រូវបានទទួលស្គាល់នៅក្នុង ICCPR អាចបង្គ្រប់ជានីតិវិធី និងនឹងប៉ះពាល់ដល់ផលប្រយោជន៍របស់ជនត្រូវចោទ"*[21]។

១៦. នៅក្នុងករណីនេះ កំហុសទូទៅដែលបានចោទនេះកើតចេញពីសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី តាមរយៈការត្រួតពិនិត្យកំណត់ហេតុស្តាប់ចម្លើយចំនួន ២៦ នៅក្នុងសំណើសុំធ្វើប្រតិចារិក ដែលមេធាវីការពារក្តី បានបង្ហាញពីការចោទប្រកាន់អំពីភាពខុសគ្នាចំនួន ១១២ រវាងកំណត់ហេតុស្តាប់ចម្លើយ ជាមួយនឹងខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយ។ ខ្ញុំបានសម្រេចថា ការចោទប្រកាន់ទាំងនោះភាគច្រើនមិនមានមូលដ្ឋាន៖ ការត្រួតពិនិត្យរបស់ខ្ញុំទៅលើកំហុសចំនួន ១១២ ដែលបានចោទនៅក្នុងសំណើសុំធ្វើប្រតិចារិក បានរកឃើញតែករណីមួយចំនួនតូចប៉ុណ្ណោះដែលមានភាពខុសគ្នាជាក់ស្តែងរវាងខ្សែអាត់សំឡេង ជាមួយនឹងកំណត់

[20]សំណុំរឿង០០៣ ឯកសារ D134/1/10 *សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [កោសលុប] ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់[កោសលុប]ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ* ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ២០។

[21]សំណុំរឿង០០២ ឯកសារ D55/I/8 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព* ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ៤០។ *សូមមើលផងដែរ* សំណុំរឿង០០២ ឯកសារ D263/2/6 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1)* ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១០ កថាខណ្ឌ ២១។ សំណុំរឿង០០២ ឯកសារ D257/1/8 *សេចក្តីពិចារណាលើសំណើរបស់ តា អាន សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ* ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ កថាខណ្ឌ ៣៤។

ហេតុស្តាប់ចម្លើយ ដែលភស្តុតាងត្រូវបានបំប្លែង ឬភស្តុតាងពាក់ព័ន្ធមិនបានបញ្ចូលទៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ប៉ុន្តែទោះជាក្នុងករណីបែបនេះក៏ដោយ ក៏ខ្ញុំបានរកឃើញថា ភាពខុសគ្នាទាំងនោះជារឿយៗមិនមានលក្ខណៈធ្ងន់ធ្ងរ ឬជាក់ស្តែងសំខាន់ឡើយ[22]។ ខ្ញុំបានសន្និដ្ឋានថា មេធាវីការពារក្តី មិនបានបង្ហាញពីអត្ថិភាពនៃឧទាហរណ៍អំពី"*ការអនុវត្តកិច្ចស៊ើបសួរដោយពុំត្រឹមត្រូវដែលមានជាច្រើនចំណុច និងគួរឱ្យកត់សម្គាល់*"ទេ ហើយ ខ្ញុំយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយដែលបានបង្ហាញនៅក្នុងសំណើសុំធ្វើប្រតិចារិក ជាទូទៅគឺត្រឹមត្រូវ ពេញលេញ អាចជឿជាក់បាន និងអនុវត្តតាមវិធានដែលចែងអំពីកំណត់ហេតុស្តាប់ចម្លើយនៅ អ.វ.ត.ក[23]។

១៧. ខ្ញុំជឿជាក់ថា មេធាវីការពារក្តី មានទឡ្ហីករណ៍ដែលមានសំអាងហេតុដើម្បីគាំទ្រការអះអាងដែលថា ការមិនបានថតសំឡេងការស្តាប់ចម្លើយមួយចំនួននៅក្នុងសំណុំរឿង០០៤ បានរំលោភសិទ្ធិរបស់ អោ អាន ដែលបានធានាតាមកតិកាសញ្ញា ICCPR ហើយសំណើសុំមោឃភាពបានបំពេញតាមលក្ខខណ្ឌដើម្បីបញ្ជូនទៅអ.ប.ជ យោងតាមវិធានផ្ទៃក្នុង៧៦(២)។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

១៨. **អនុញ្ញាតតាម** សំណើសុំមោឃភាព។

១៩. **បង្គាប់** ក្រឡាបញ្ជីរបស់ ក.ស.ច.ស ត្រូវបញ្ជូនសំណុំរឿង ០០៤ ជូនទៅអង្គបុរេជំនុំជម្រះ យោងតាមវិធានផ្ទៃក្នុង ៧៦(៣)។

ភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**

---

[22] ដីកាសម្រេចលើសំណើសុំធ្វើប្រតិចារិក កថាខណ្ឌ ៩៧-៩៨។

[23] ដីកាសម្រេចលើសំណើសុំធ្វើប្រតិចារិក កថាខណ្ឌ ១០០។